ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៤១...អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកែសម្រួលមាត្រា១០ និងមាត្រា១១ នៃអនុក្រឹត្យលេខ២២២ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំយន្តការគ្រប់គ្រង កម្រិតថ្នាក់ និងកំណត់ប្រាក់កម្រៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ២៩អនក្រ.បក ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០២ ស្តីពីបទវិន័យទូទៅសម្រាប់កងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ២២២ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំយន្តការគ្រប់គ្រង កម្រិតថ្នាក់ និងកំណត់ប្រាក់កំរៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ

- បានឃើញអនុក្រឹត្យលេខ ៨៩អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១០អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៧ ស្តីពីការកម្រិតរបបម៉ោងកំណត់ ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រាមួយ .-**

មាត្រា១០ មាត្រា១១នៃអនុក្រឹត្យលេខ ២២២អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំយន្តការគ្រប់គ្រងកម្រិតថ្នាក់ និងកំណត់ប្រាក់កម្រៃម៉ោងបង្រៀនសម្រាប់យោធាចារ្យ ត្រូវបានកែសម្រួលដូចតទៅ៖

**មាត្រា១០ .-ថ្មី**

យោធាចារ្យកងយោធពលខេមរភូមិន្ទក្នុងក្របខណ្ឌ អាចបង្រៀនទទួលប្រាក់កម្រៃយ៉ាងច្រើនបំផុត៤៨ម៉ោងក្នុងមួយខែ។

នាយទាហាននៃកងយោធពលខេមរភូមិន្ទមិនស្ថិតក្នុងក្របខណ្ឌយោធាចារ្យ រាល់ការអញ្ជើញមកបង្រៀនទទួលបានប្រាក់កម្រៃយ៉ាងច្រើនបំផុត៣២ម៉ោងក្នុងមួយខែ។

គ្រូបង្រៀន សាស្ត្រាចារ្យ មន្ត្រីរាជការស៊ីវិល អ្នកច្បាប់ ឬអ្នកមានចំណេះដឹងវិទ្យាសាស្ត្របច្ចេកទេស រាល់ការអញ្ជើញមកបង្រៀនទទួលបានប្រាក់កម្រៃយ៉ាងច្រើនបំផុតចំនួន៥០ម៉ោងក្នុងមួយខែ។

ប្រាក់កម្រៃម៉ោងបង្រៀនខាងលើគិតតាមកម្រិតសញ្ញាបត្រ និងតាមក្របខណ្ឌតួនាទី ត្រូវបានទទួលប្រាក់កម្រៃម៉ោងបន្ថែមក្នុងមួយម៉ោងដូចមានកំណត់ក្នុងតារាងខាងក្រោម៖

| កម្រិតសិក្សា / សញ្ញាបត្រ ឬឋានៈ | បណ្តុះបណ្តាល-បំប៉នកម្រិតបឋម | បណ្តុះបណ្តាល-បំប៉នកម្រិតមធ្យម | បណ្តុះបណ្តាល-បំប៉នកម្រិតឧត្តម |
|---|---|---|---|
| សាស្ត្រាចារ្យថ្នាក់បណ្ឌិត ឬថ្នាក់អគ្គនាយកឡើងទៅ | ២៥ ០០០៛ (ពីរម៉ឺនប្រាំពាន់)រៀល | ៣៥ ០០០៛ (បីម៉ឺនប្រាំពាន់)រៀល | ៤០ ០០០៛ (បួនម៉ឺន)រៀល |
| សាស្ត្រាចារ្យថ្នាក់អនុបណ្ឌិត ឬក្របខណ្ឌ ឧ១.៤ ឬថ្នាក់នាយកដ្ឋាន | ១៨ ០០០៛ (មួយម៉ឺនប្រាំបីពាន់)រៀល | ១៨ ៦០០៛ (មួយម៉ឺនប្រាំបីពាន់ប្រាំមួយរយ)រៀល | ២០ ៨០០៛ (ពីរម៉ឺនប្រាំបីរយ)រៀល |
| សាស្ត្រាចារ្យថ្នាក់ឧត្តម ឬក្របខណ្ឌ ឧ១.១ ឧ១.៣ ឬថ្នាក់ប្រធានការិយាល័យ | ៩ ០០០៛ (ប្រាំបួនពាន់)រៀល | ១០ ៤០០៛ (មួយម៉ឺនបួនរយ)រៀល | ១៥ ០០០៛ (មួយម៉ឺនប្រាំពាន់)រៀល |
| គ្រូជំនាញឯកទេស ឬនាយទាហានថ្នាក់អនុប្រធានការិយាល័យចុះ | ៥ ៥០០៛ (ប្រាំពាន់ប្រាំរយ)រៀល | ៥ ៥០០៛ (ប្រាំពាន់ប្រាំរយ)រៀល | ៥ ៥០០៛ (ប្រាំពាន់ប្រាំរយ)រៀល |

ការគ្រប់គ្រងនិងការប្រើប្រាស់របបម៉ោងបន្ថែម ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងក្រសួងការពារជាតិ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១១ ._ថ្មី**

កំណត់ប្រាក់កម្រៃចងក្រងឯកសារ និងបកប្រែភាសាបរទេសសម្រាប់បម្រើការងារហ្វឹកហ្វឺន រៀនសូត្រក្នុងមួយទំព័រឯកសារវាយកុំព្យូទ័រខ្នាតក្រដាស " A4 " ត្រូវទទួលបានប្រាក់កម្រៃដូចតទៅ៖

-លើកិច្ចការស្រាវជ្រាវចងក្រងចំនួន ២០.០០០រ(ពីរម៉ឺន)រៀល ក្នុងមួយទំព័រ

-លើកិច្ចការបកប្រែឯកសារចំនួន ១២.០០០(មួយម៉ឺនពីរពាន់)រៀល ក្នុងមួយទំព័រ។

ចំពោះការសរសេរសេចក្ដីសង្ខេប... 

**មាត្រាពីរ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៧កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែ មីនា ឆ្នាំ២០១៩

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្ដេចពិជ័យសេនា ទៀ បាញ់**

**កន្លែងទទួល** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទការល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទការល័យសម្ដេច ឯកឧត្ដម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រាបី
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ